**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

លេខ...៥៥៤.........ស.ន.ប

# ប្រកាស
## ស្តីពី
## ការផ្ទេរប្រតិភូកម្មមុខងារនៃវិស័យសុខាភិបាលនៅមណ្ឌលសុខភាព ជូនរដ្ឋបាលស្រុកគោលដៅ

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បានឃើញព្រះរាជក្រមលេខ នស/រកត/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

-បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល

-បានឃើញសេចក្តីសម្រេចលេខ ០៧៧ សសរ/គ.ជ.អ.ប ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៤ របស់គណៈកម្មាធិការសម្រាប់ការអភិវឌ្ឍន៍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ស្តីពីការកំណត់ស្រុកគោលដៅសម្រាប់អនុវត្តគម្រោងស្តីពីកិច្ចអនុវត្តមូលដ្ឋានតាមរយៈការផ្ទេរមុខងារសេវាសុខាភិបាល

### សម្រេច

**ប្រការ១.-**

ត្រូវបានផ្ទេរប្រតិភូកម្មមុខងារមួយចំនួនរបស់មណ្ឌលសុខភាព ឲ្យដល់ស្រុកគោលដៅ ចំនួនប្រាំ ( ០៥ ) ក្នុងការអនុវត្តគម្រោងស្តីពីកិច្ចអភិវឌ្ឍន៍មូលដ្ឋានតាមរយៈការផ្ទេរមុខងារសេវាសុខាភិបាល គឺស្រុកមោងឫស្សី ស្រុកគាស់ក្រឡ និងស្រុករុក្ខគិរី នៃខេត្តបាត់ដំបង ស្រុកបាកាន និងស្រុកកណ្តៀង នៃខេត្តពោធិ៍សាត់ ។

ទីស្តីការក្រសួងសុខាភិបាល, លេខ ១៥១-១៥៣ វិថីកម្ពុជាក្រោម ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៦៦ ០៧៥ / ៨៨៥ ៤០៥ ទូរស័ព្ទ: (៨៥៥-២៣) ៧២២ ៨៧៣

**ប្រការ២.-**

មុខងារសុខាភិបាលរបស់មណ្ឌលសុខភាព ដែលត្រូវធ្វើប្រតិភូកម្មក្នុងគម្រោងសាកល្បង មាន ៖

-ការថែទាំមណ្ឌលសុខភាព រួមបញ្ចូលទាំងសេវាអនាម័យ អគ្គិសនី និងទឹក

-ការផ្តល់ការលើកទឹកចិត្ត និងការគាំទ្រដល់គណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាព និងក្រុមទ្រទ្រង់សុខភាពភូមិ

-ការផ្តល់ការលើកទឹកចិត្តដល់បុគ្គលិកមណ្ឌលសុខភាព

-ការលើកស្ទួយ និងបន្ថែមសេវា ដូចជាការគាំពារ សេវាសុខភាពសហគមន៍ និងប្រចាំការ ២៤ម៉ោង

-ការពង្រឹងយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការផ្តល់សេវា នៅមណ្ឌលសុខភាព និងសេវាសុខភាពនៅសហគមន៍ ។

**ប្រការ៣.-**

មុខងារលម្អិតដែលមានចែងក្នុងប្រការ២ មានកំណត់ក្នុងសេចក្តីណែនាំស្តីអំពីសំណុំសកម្មភាព អប្បបរមាសម្រាប់ការអភិវឌ្ឍន៍មណ្ឌលសុខភាព ។

នីតិវិធីនៃការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តន៍មុខងារ ដូចមានចែងក្នុងប្រការ២ ជាសមត្ថកិច្ចរបស់ក្រុមការងារបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការ ក្រសួងសុខាភិបាល សហការជាមួយលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ( គ.ជ.អ.ប ) ។

**ប្រការ៤.-**

ប្រកាសនេះអនុវត្តក្នុងគម្រោងសាកល្បងរយៈពេល ដប់ប្រាំមួយខែ ( ១៦ ខែ ) ចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៤ ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ។

**ប្រការ៥.-**

អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសសុខាភិបាល អគ្គាធិការក្រសួងសុខាភិបាល ប្រធានមន្ទីរសុខាភិបាលខេត្ត ប្រធានការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ ប្រធានមណ្ឌលសុខភាព និងអ្នកពាក់ព័ន្ធទទួលខុសត្រូវគ្រប់លំដាប់ថ្នាក់ នៃស្រុកគោលដៅ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តតាមប្រកាសនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១០ ខែ តុលា ឆ្នាំ២០១៤

ម៉ម_ប៊ុនហេង

**ចម្លងជូន:**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ខុទ្ទកាល័យក្រសួងសុខាភិបាល

-លេខាធិការដ្ឋាន គ.ជ.អ.ប

-សាលាខេត្តបាត់ដំបង

-សាលាខេត្តពោធិសាត់

-ដូចប្រការ៥ " ដើម្បីអនុវត្ត "

-ឯកសារ-កាលប្បវត្តិ